រាជបណ្ឌិត្យសភាកម្ពុជា

# ការសិក្សាពីសំណេរពាក្យកម្លាយនៃភាសាខ្មែរទំនើប ក្នុងក្របខ័ណ្ឌ *សំរាយតំរូត*

# The Study of Written Derivatives in The Modern Khmer Language of The Condition of Samray-Damrout

ផល សុភឿន

និក្ខេបបទបណ្ឌិត

ជំនាញ : ភាសាវិទ្យា

គ្រូណែនាំ : បណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ

ឆ្នាំ២០២៤

# មាតិកា

ឧទ្ទិសស្នាដៃ........................................................................................................I
សេចក្តីថ្លែងអំណរគុណ ..............................................................................................II
អំណះអំណាង........................................................................................................III
អារម្ភកថា ..............................................................................................................IV
មូលន័យសង្ខេប ........................................................................................................V
**សេចក្តីផ្តើម**................................................................................................... ១
១- លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ........................................................................ ១
២- ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ..................................................................... ៨
៣- គោលបំណងនៃការសិក្សាស្រាវជ្រាវ .......................................................................១០
៤- ដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ .....................................................១២
៥- វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ.............................................................................១៣
-វិធីសាស្ត្រប្រមូលទិន្នន័យ………………………………………………………………. ១៣
-វិធីសាស្ត្រវិភាគទិន្នន័យ………………………………………………………………….១៧
៦- សារប្រយោជន៍នៃការសិក្សាស្រាវជ្រាវ.....................................................................១៩
៧- រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ.........................................................................២០

## ជំពូកទី១

## ទ្រឹស្តីដែលពាក់ព័ន្ធនឹងសំណោរពាក្យ

**១.១- និយមន័យ**…………………………………………………………………………….២២
-សំណោរពាក្យ………………………………………………………………………….២២
-សំណោរ……………………………………………………………………………… ២៤
-ការសរសេរ…………………………………………………………………………… ២៤
-ពាក្យ…………………………………………………………………………………. ២៦
-ពាក្យកម្លាយ………………………………………………………………………….២៧
**១.២- ក្របខណ្ឌទ្រឹស្តីនានាពាក់ព័ន្ធនឹងប្រធានបទ**……………….. ……..២៨
១.២.១- ទស្សនៈរបស់ *Nattaya Piriyawiboon* ………………………..……… ២៨
១.២.២- ទស្សនៈរបស់ ***Dr. Preecha Khanetnok*** ……………….……………… ២៨
១.២.៣- ទស្សនៈរបស់ **Martin Haspelmath and Andrea D. Sims**………… ២៩
១.២.៤- ទស្សនៈរបស់លោក **Andrew Spenser** ………………………………… ២៩
១.២.៥- ទស្សនៈសម្តេចព្រះសង្ឃរាជ ជួន ណាត ………………………………… ២៩
១.២.៦- ទស្សនៈខេមរយានកម្ម ……………………………………………… ៣១

១.២.៧- ទស្សនៈលោក អៀវ កើស ................................................ ៣៤
១.២.៨- ទស្សនៈបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ ................................ ៣៧
ក- រំលឹកពីទ្រឹស្តីបរន្តេនិយម .................................................. ៤១
ខ- ការអនុវត្តទ្រឹស្តីបរន្តេនិយមលើការសិក្សាពីប្រធានបទ ..................... ៤៤
១.៣- សេចក្តីសន្និដ្ឋាន ...........................................................៤៨

## ជំពូកទី២
## និដ្ឋភាពប្រវត្តិនៃការសរសេររាយត្រួត

**២.១- វិចារណកម្មលើនិដ្ឋភាពប្រវត្តិនៃការសរសេររាយត្រួត**........ ៥១
**២.២- ជុំវិញសញ្ញាណនៃសំរាយតំរួត**........................................៥២
**២.៣- បច្ចេកសព្ទក្នុងក្របខ័ណ្ឌសំរាយតំរួត**.................................. ៥៤
**២.៤- រាយត្រួតតួអក្សរ**............................................................ ៥៧
២.៤.១- តាមសំរាយតំរួត................................................ ៥៨
២.៤.២- តាមបែបប្រពៃណី................................................ ៦០
**២.៥- អំពីអ្វីដែលហៅថា *ព្យាង្គតំរួតក្នុងសម័យខេមរយានកម្ម***........ ៦៣
**២.៦- សំណេរពាក្យកម្ចាយក្នុងវចនានុក្រម**.................................៦៤
**២.៧- សំណេរពាក្យកម្ចាយក្នុងសៀវភៅសិក្សានិងឯកសារនានា**......៦៦
**២.៨- សំណេរពាក្យកម្ចាយជាឈ្មោះឬជាប្រពៃណី**........................ ៦៩

## ជំពូកទី៣
## ការវិភាគសំណេរពាក្យតាមគោលការណ៍នានា

**៣.១- ការវិភាគសំណេរពាក្យតាមគោលការណ៍អាស្រ័យឫស**............៧២
**៣.២- ការវិភាគជាប្រព័ន្ធលើនិដ្ឋភាពនៃគោលការណ៍អាស្រ័យឫស**៧៤
៣.២.១- វិភាគលើការអនុវត្តគោលការណ៍អាស្រ័យឫស..................................៧៦
៣.២.២- វិភាគសំណេរពាក្យកម្ចាយក្នុងគោលការណ៍អាស្រ័យឫស.................... ៧៩
៣.២.៣- វិភាគលើគោលការណ៍អាស្រ័យឫស.................................... ៨៥
ក- ឫសជាព្យាង្គរាយ តែពាក្យកម្ចាយបែរជាសរសេរជាព្យាង្គតំរួត................ ៨៥
ខ- ឫសជាព្យាង្គរាយ តែពាក្យកម្ចាយបែរជាសរសេរជាតំរួតព្យាង្គ................ ៨៦
គ- ឫសជាព្យាង្គតំរួត តែសំណេរនៃពាក្យកម្ចាយបែរជាសរសេរតាមរាយព្យាង្គ... ៨៧
ឃ- ឫសជាព្យាង្គរាយ តែសំណេរនៃពាក្យកម្ចាយមួយអាចសរសេរជារាយព្យាង្គផងជា

តំរួតព្យាង្គផង................................................................ ៨៨
ង- ឫសជាព្យាង្គរាយ តែសំណេរនៃពាក្យកម្លាយខ្លះ សរសេរជារាយព្យាង្គហើយខ្លះ
ទៀតសរសេរជាតំរួតព្យាង្គ...................................................... ៨៩

**៣.៣- ការវិភាគសំណេរពាក្យតាមគោលការណ៍អាស្រ័យផ្នត់**........... ៨៩
**៣.៣.១- ករណីផ្នត់ដើមដែលមានទម្រង់[ព-]**........................................ ៩១
ក- ពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ព-].................. ៩២
ខ- វិភាគសំណេរនៃពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ព-]... ៩៤
**៣.៣.២- ករណីផ្នត់ដើមដែលមានទម្រង់[ពស-]**...................................... ៩៦
ក- ពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ពស-]................ ៩៨
ខ- វិភាគសំណេរនៃពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ពស-] ៩៩
**៣.៣.៣- ករណីផ្នត់ដើមដែលមានទម្រង់[ពសព-]**.....................................១០១
ក- ពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ពសព-]............... ១០៣
ខ- វិភាគសំណេរពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ពសព-] ១០៥
**៣.៣.៤- ករណីផ្នត់ដើមដែលមានទម្រង់[ពពស-]**..................................... ១០៨
ក- ពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ពពស-]............. ១០៩
ខ- វិភាគសំណេរពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដើមទម្រង់[ពពស-] ១១១
**៣.៣.៥- ករណីផ្នត់ដែកដែលមានទម្រង់[-ព-]**...................................... ១១៤
ក- ពាក្យកម្លាយដែលកើតឡើងតាមរយៈផ្នត់ដែកដែលមានទម្រង់[-ព-]... ១១៥
ខ- វិភាគពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដែកដែលមានទម្រង់[-ព-]... ១១៧
**៣.៣.៦- ករណីផ្នត់ដែកដែលមានទម្រង់[-សព-]**.................................. ១១៨
ក- ពាក្យកម្លាយដែលកើតឡើងតាមរយៈផ្នត់ដែកដែលមានទម្រង់[-សព-] ១១៩
ខ- វិភាគពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដែកដែលមានទម្រង់[-សព-] ១២០
**៣.៣.៧- ករណីផ្នត់ដែកដែលមានទម្រង់[-ស/ព-]**................................. ១២០
ក- ពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដែកដែលមានទម្រង់[-ស/ព-]...... ១២១
ខ- វិភាគពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដែកដែលមានទម្រង់[-ស/ព-]១២២
**៣.៣.៨- ករណីផ្នត់ដែកដែលមានទម្រង់[-សព/ព-]**............................. ១២៤
ក- ពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដែកដែលមានទម្រង់[-សព/ព-]... ១២៦
ខ- វិភាគពាក្យកម្លាយកើតឡើងតាមរយៈផ្នត់ដែកមានទម្រង់[-សព/ព-]... ១២៨
៣.៣.៩- សន្និដ្ឋានលើសំណេរនៃពាក្យកម្លាយតាមគោលការណ៍អាស្រ័យផ្នត់........ ១៣០

**៣.៤- ការវិភាគសំណេរពាក្យកម្លាយតាមទ្រឹស្តីបរន្តេនិយម**........... ១៣៤

៣.៤.១- ការវិភាគពីចលនាសកម្មទ្វេទិសនៃធាតុរបស់ពាក្យកម្ចាយតាមរយៈផ្នត់ក្នុងទម្រង់ [ព-]និង[-ព-]………………………………………………………… ១៣៧
៣.៤.២- ការវិភាគពីចលនាសកម្មទ្វេទិសនៃធាតុរបស់ពាក្យកម្ចាយតាមរយៈផ្នត់ដែកក្នុង ទម្រង់[-សព-]………………………………………………………… ១៤១
៣.៤.៣- ការវិភាគពីចលនាសកម្មទ្វេទិសនៃធាតុរបស់ពាក្យកម្ចាយតាមរយៈផ្នត់ដែកក្នុង ទម្រង់[-ស/ព-]………………………………………………………… ១៤៥
៣.៤.៤- ការវិភាគពីចលនាសកម្មទ្វេទិសនៃធាតុរបស់ពាក្យកម្ចាយតាមរយៈផ្នត់ដែកក្នុង ទម្រង់[-សព/ព-]………………………………………………………… ១៥០
៣.៤.៥- សន្និដ្ឋានលើការវិភាគពាក្យកម្ចាយតាមចលនាសកម្មទ្វេទិស……………… ១៥៣
**៣.៥- ការវិភាគជាប្រព័ន្ធទៅលើឧទាហរណ៍នៃទិន្នន័យ**………………… ១៥៥
៣.៥.១- កត្តាដែលនាំឱ្យពាក្យកម្ចាយមានសំណេរជាព្យាង្គតំរួត………… ១៥៩
៣.៥.២- កត្តាដែលនាំឱ្យពាក្យកម្ចាយមានសំណេរជារាយព្យាង្គ………… ១៦១
៣.៥.៣- កត្តាដែលនាំឱ្យពាក្យកម្ចាយមានសំណេរជាតំរួតព្យាង្គ………… ១៦៣
**សេចក្តីសន្និដ្ឋាន**………………………………………………………………… ១៦៤
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# **បញ្ជីអក្សរកាត់**

ប្រើក្នុងនិក្ខេបបទនេះ

ព = ព្យញ្ជនៈនៃផ្នត់

ស = ស្រៈនៃផ្នត់

[ព-] = ផ្នត់ដើមទម្រង់**ព**

[ពស-] = ផ្នត់ដើមទម្រង់**ពស**

[ពសព-] = ផ្នត់ដើមទម្រង់**ពសព**

[ពពស-] = ផ្នត់ដើមទម្រង់**ពពស**

[-ព-] = ផ្នត់ដែកទម្រង់**ព**

[-សព-] = ផ្នត់ដែកទម្រង់**សព**

[-ស/ព-] = ផ្នត់ដែក**ស/ព** ( ព្យាង្គកាត់ ស/ព )

[-សព/ព-] = ផ្នត់ដែក**សព/ព** ( ព្យាង្គកាត់ សព/ព )

[ក-] = ផ្នត់ដើម/**ក**/

[-ន-] = ផ្នត់ដែក/**ន**/

[-អ'ម-] = ផ្នត់ដែក***[-អ'ម-]***

/អ'ម/  = ការកត់ត្រាសូរ/អ'ម/

អ'ម    = សំដៅលើ ស្រៈអ'ម ( ំ )

-ដ-ឯ-ម- = ដូចឯកសារដើម

*API = Alphabet Phonétique International*

# ឧទ្ទិសកថា

ខ្ញុំព្រះករុណាអាត្មាភាព **ផល សុវឿន** ជាសមណនិស្សិតថ្នាក់បណ្ឌិត ជំនាញភាសាវិទ្យា ជំនាន់ទី១ វគ្គ២ នៃរាជបណ្ឌិត្យសភាកម្ពុជា ទីស្ដីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមចម្រើនពរលើកនូវបុណ្យកុសលនិងឧទ្ទិសស្នាដៃនេះ គោរពជូនដល់វិញ្ញាណក្ខន្ធឧទ្ទេសាចារ្យ ស៊ិន សារិន គ្រូអាចារ្យបង្រៀនភាសាបាឡីនៅពុទ្ធិកបឋមសិក្សាវត្តនាគវ័ន រាជធានីភ្នំពេញ ដែលជាជីតាបង្កើត។

ប្រគេនថ្វាយស្នាដៃនេះចំពោះ៖

-ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រគ្រប់ជំនាន់

-ព្រះវិញ្ញាណក្ខន្ធបុព្វសមណៈ មានសម្តេចព្រះសង្ឃរាជ ជួន ណាត ជាដើម

-វិញ្ញាណក្ខន្ធសាស្ត្រាចារ្យលោកគ្រូអ្នកគ្រូលោកលោកស្រីអ្នកស្នេហាអក្សរសាស្ត្រជាតិគ្រប់ជំនាន់។

-វិញ្ញាណក្ខន្ធវីរបុរសដែលបានលះបង់កាយថ្វាយជីវិតចំពោះជាតិមាតុភូមិ។

-វិញ្ញាណក្ខន្ធញាតកាលសន្តាន។

សូមបុណ្យគុណកុសលដែលកើតចេញពីស្នាដៃនេះ បានផ្សព្វផ្សាយបន្សាយដល់ព្រះវិញ្ញាណក្ខន្ធនិងវិញ្ញាណក្ខន្ធព្រះតេជព្រះគុណអស់លោកអ្នកមានគុណចំពោះជាតិ សាសនា ព្រះមហាក្សត្រទាំងអស់ស្ថិតក្នុងសិវស្ថានសុគតិកុំបីឃ្លៀងឃ្លាតឡើយ។

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ :

លោកឪពុក **ហេង សុផល** និង អ្នកម្តាយ **រិន ចាន់ណា** ដែលបានផ្តល់កំណើតដល់អាត្មាភាពដែលលោកទាំងទ្វេជាបុព្វាចារ្យ ជាទេព្វាចារ្យ ជាអាហុនេយ្យបុគ្គល ដែលប្រកបដោយព្រហ្មវិហារធម៌និងធម្មសង្គ្រោះមានមុទិតាជាឧត្តមធម៌។

បណ្ឌិតសភាចារ្យ **ច័ន្ទ សំណាព្វ** ជាគ្រូបាអាចារ្យដែលបានបើកបង្ហាញបង្ហាត់បង្រៀនជួយជំរុញណែនាំនិងផ្តល់ចំណេះដ៏ឧត្តមក្នុងផ្នែកភាសាវិទ្យា ជាបរមាចារ្យបង្កើតគំនិតជាប្រព័ន្ធ លោកជាបញ្ញវន្តដ៏ជាគំរូ និងជាគ្រូណែនាំក្នុងការសរសេរនិក្ខេបបទនេះ ដោយវិរិយៈឧស្សាហៈមិនខ្លាចនឿយហត់រហូតទទួលបានលទ្ធផលល្អក្នុងពេលនេះ។

ព្រះឧបាលិវង្ស **ម៉័ង្ គីមសន** ព្រះរាជាគណៈថ្នាក់ត្រី ព្រះអនុគណខណ្ឌពោធិ៍សែនជ័យដែលបានជួយជ្រោមជ្រែង ផ្តល់មតិយោបល់ និងផ្តល់ឱកាសឱ្យខ្ញុំព្រះករុណាបានដឹកនាំ នៅអាវាសវត្តព្រៃស្ពឺរហូតមក។

រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជាប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលប្រកបដោយបញ្ញាញាណឈ្លាសវៃភ្លឺថ្លា ប្រកបដោយគតិបណ្ឌិត ដែលនាំអាណាប្រជារាស្ត្របានសុខក្នុងម្លប់សន្តិភាព។

ឯកឧត្តមបណ្ឌិតសភាចារ្យ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ជាប្រធាន ជាសមាជិកនៃគណៈកម្មការវាយតម្លៃនិក្ខេបបទ ដែលបានវាយតម្លៃនិងផ្តល់អនុសាសន៍ប្រកបដោយវិជ្ជាជីវៈនិងសាស្ត្រា-ចារ្យបណ្ឌិតគ្រប់រូបដែលបានបង្ហាត់បង្រៀនតាំងពីឆមាសទី១រហូតដល់ចប់ថ្នាក់។

ទីបញ្ចប់ សូមអរព្រះគុណព្រះតេជព្រះគុណភិក្ខុសាមណេរក្នុងវត្តព្រៃស្ពឺ ព្រមទាំងគណៈកម្មការអាចារ្យនិងញាតិញោមចំណុះជើងវត្តទាំងអស់ដែលតែងតែទំនុកបម្រុង គាំទ្រ ផ្តល់ឱកាសឱ្យខ្ញុំព្រះករុណាអាត្មាភាពបន្តការសិក្សារហូតដល់ចប់។

# អំណះអំណាង

ខ្ញុំព្រះករុណាអាត្មាភាព **ព្រះវិសុទ្ធានុញ្ញាណ ផល សុធឿន** ជាសមណនិស្សិតថ្នាក់បណ្ឌិតសិក្សាជំនាញភាសាវិទ្យា ជំនាន់ទី២ វគ្គ១ នៃរាជបណ្ឌិត្យសភាកម្ពុជា (សិក្សាបង់ថ្លៃ) សូមអះអាងថានិក្ខេបបទ ៖ *“ ការសិក្សាពីសំណេរពាក្យកម្ចីនៃភាសាខ្មែរទំនើប : ក្នុងក្រុមខ័ណ្ឌ : សំរាយ - តំរួត ”* គឺជានិក្ខេបបទមួយដែលបានសិក្សាវិភាគរបស់អាត្មាភាពយ៉ាងពិតប្រាកដ ។

ថ្ងៃ...........ខែ......ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី......ខែ...... ឆ្នាំ២០២៤
ហត្ថលេខា

ថ្ងៃ...........ខែ......ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី......ខែ......... ឆ្នាំ២០២៤

**គ្រូណែនាំ**

**បណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ**

# មូលន័យសង្ខេប

ការសិក្សាលើប្រធានបទនៃនិក្ខេបបទថ្នាក់បណ្ឌិតនេះ ចង់ដោះស្រាយបញ្ហាដែលបានចោទឡើងលើបញ្ហាសំរាយតំរួតដែលមានពាក្យក្លាយសរសេរជារាយព្យាង្គ ព្យាង្គតំរួត តំរួតព្យាង្គ គឺការស្រាវជ្រាវមួយដែលចារឹកទៅក្នុងក្របខ័ណ្ឌនៃទ្រឹស្ដីច័ន្ទ សំណព្វដែលមានឈ្មោះថាទ្រឹស្ដីបរន្តេនិយម។ ខ្លឹមសារចម្បងផ្ដោតលើការវិភាគពីសំណេរពាក្យកម្លាយនៃភាសាខ្មែរទំនើបក្នុងក្របខ័ណ្ឌ *សំរាយតំរួត* ដោយផ្អែកលើកម្រងទិន្នន័យមួយប្រកបដោយពិពិធភាព។ ទស្សនៈនានាដែលបានបំពាក់ទៅលើសំណេរពាក្យជាទូទៅ ជាអាទិ៍ ទស្សនៈសម្ដេច ជួន ណាត ទស្សនៈបណ្ឌិតសភាចារ្យច័ន្ទ សំណព្វ ទស្សនៈខេមរ-យានកម្ម ត្រូវបានលើកយកមកវិភាគជាប្រព័ន្ធក្នុងគោលបំណងស្វែងយល់ដើម្បីបានឈ្វេងយល់ពីសំណេរនៃពាក្យកម្លាយនៃភាសាខ្មែរ។ ការប្រកបសូរវាងស្រៈនិងព្យញ្ជនៈក្នុងការបង្កើតព្យាង្គនៃពាក្យកម្លាយក៏ជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវនេះដែរ ដោយសារតែការប្រកបសូរនោះបានជះឥទ្ធិពលដល់សំណេរពាក្យខ្មែរក្នុងបរបទនៃសំរាយតំរួត។ របកគំហើញដែលបានកើតចេញពីការសិក្សាស្រាវជ្រាវលើប្រធានបទនេះ អាចជានិយ័តករនៃទស្សនៈទាំងឡាយដែលប្រឈមគ្នាក្នុងគ្រាកន្លងមក។

ជាការពិតណាស់ ប្រធានបទនៃការស្រាវជ្រាវក្នុងនិក្ខេបបទនេះ ជាផ្នែកដ៏តូចមួយ បើធៀបទៅនឹងវិសាលភាពនៃភាសាខ្មែរទាំងមូល។ ប៉ុន្តែ របកគំហើញដែលបានមកពីការសិក្សាលើប្រធានបទនេះ បាននាំមកនូវប្រព័ន្ធគំនិតដែលបានគ្របដណ្ដប់លើទិដ្ឋភាពជាច្រើននៃភាសាខ្មែរ ជាអាទិសំណេរពាក្យ អក្ខរាវិរុទ្ធ តួនាទីនៃផ្នត់ក្នុងការកម្លាយពាក្យ។ ទន្ទឹមនឹងនេះ ការស្រាវជ្រាវលើប្រធានបទនេះក៏បានបំភ្លឺពីគម្លាតរវាងទស្សនៈ ដែលបង្ហាញទៅលើភាសាតាមបែបអត្តនោម័តនិងតាមបែបសត្យានុម័ត ដូចមានរំលេចចេញតាមរយៈគោលការណ៍អាស្រ័យឫសនិងគោលការណ៍អាស្រ័យផ្នត់ជាសក្ខីភាពស្រាប់។ មិនតែប៉ុណ្ណោះ ការអនុវត្តទ្រឹស្ដីបរន្តេនិយមបាននាំមកនូវការយល់ដឹងពីសុក្រឹតភាពនិងសកលភាពនៃក្បួនខ្នាតភាសាខ្មែរ ព្រមទាំងជម្រះបាននូវការយល់ច្រឡំនានាដែលធ្លាប់មានក្នុងគ្រាកន្លងមក។

ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ :

បញ្ហាទាក់ទងនឹងកម្លាយពាក្យខ្មែរដែលអាចកម្លាយជារាយឬត្រួតដែលបានសិក្សាមកបានបង្ហាញថា :

គោលការណ៍អាស្រ័យឫសដែលយកពាក្យឫសជាកត្តាសំខាន់ក្នុងការកម្លាយពាក្យខ្មែរ គឺមិនអាចអនុវត្តបានដោយទូទៅនិងក្នុងទិដ្ឋភាពនៃការកម្លាយពាក្យខ្មែរនោះទេ។

គោលការណ៍អាស្រ័យផ្នត់ដែលពាក្យឫសក្នុងបរន្តេកម្មជាមួយនឹងផ្នត់ កង្កើតបានជាពាក្យកម្លាយដែលអាចជារាយឬត្រួតក្នុងភាសាខ្មែរ ដែលគោលការណ៍នេះអាចយកមកអនុវត្តបានក្នុងគ្រប់ទិដ្ឋភាពនៃពាក្យកម្លាយក្នុងភាសាខ្មែរ។

# Abstract

The study on the subject of this doctoral dissertation we want to resolve the problem that arises on the problem of solving of ***Samray-Damruot*** whose words become written in រាយព្យាង្គ, ព្យាង្គតំរួត, តំរួតព្យាង្គ, is research written within the framework of Chan Somnoble's theory called *Theory of Extintraism*. The main content focuses on the analysis of the writings of derivative words in modernized Khmer language within the framework of ***Samray-Damruot***, based on a database of diversification. General perspectives regarding writing work, including Samdech Chuon Nath's perspective, Dr. Chan Somnoble's perspectives, Khmerization's perspective, are systematically analyzed in order to figure out to achieve understandings of Khmer's writings of derivative words. Phonetic pronunciation between vowels and consonants to form syllables of a derivative word is also a part of this research, for pronunciation has influenced the writings of khmer words in Extet.The findings emerging from a study on this subject can be a regulator of all views that have been opposing each other.

The topic of research in this thesis is a small part of the scope of the Khmer language as a whole. But the findings from the study of this topic have brought about a comprehensive conceptual system that covers many aspects of the Khmer language, primarily, spelling, and the role of affix in derivatives. At the same time, research on this topic also sheds light on the gaps between subjective and objective language perspectives, as evidenced by the root-based and affix-based principles. Moreover, the application of Extintraism theory has brought an understanding of the accuracy and universality of the Khmer language rules, as well as cleared up any misunderstandings that have existed in the past.

As the result of the study:

Problems related to the transformation of Khmer words that can be transformed individually or repeatedly studied as follows:

The root-based principle, which takes the word root as an important factor in transforming Khmer words, is not applicable in general and in terms of transforming Khmer words.

The principle depends on the fold in which the word root in the transformation with the fold generates a transformation of words that can be individual words or overlapped words in Khmer, this principle can be applied in all aspects of the word transformation in Khmer.

# សង្ខេបនិក្ខេបបទ

ការសរសេរពាក្យកម្លាយ ជារាយព្យាង្គនិងជាតំរួតព្យាង្គជាបញ្ហាដែលចោទមានឡើងនៅក្នុងភាសាខ្មែរក្នុងប៉ុន្មានទសវត្សកន្លងមកនេះ។ ជាក់ស្តែង *ចំការ លំអ សំអាង* ដែលមានសំណេរជារាយព្យាង្គដូចគ្នា តែស្តែងពីបាតុភូតខុសៗគ្នា ដោយធៀបទៅនឹង *ចម្ការ លម្អ សម្អាង* ដែលមានសំណេរជាតំរួតព្យាង្គ៖ *ចំការ* ជាសំណេរប្រវត្តិសាស្ត្រដែលគ្មានចែងនៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ដូច *ចម្ការ*វីឯ *លំអ* និង *លម្អ* ជាសំណេរដែលមានកត់ត្រាទុកក្នុងវចនានុក្រមថាជាពាក្យតែមួយ ពោលគឺមានន័យដូចគ្នា ហើយករណីទាំងពីរនេះខុសស្រលះពី *សំអាង* និង *សម្អាង* ដែលមានវត្តមាននៅក្នុងវចនានុក្រមដដែលនេះ តែជាពាក្យពីរផ្សេងគ្នានិងមានន័យផ្សេងគ្នា។

ដើមចមដែលនាំឱ្យមាននូវសំណេរពាក្យកម្លាយជារាយព្យាង្គនិងជាតំរួតព្យាង្គ ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងគោលការណ៍អាស្រ័យផ្នត់ ដែលលុះទៅដោយស្មារតីនៃទ្រឹស្តីច័ន្ទ សំណព្វដែលស្ថាបនិកនៃទ្រឹស្តីនេះដែលអាចហៅបានថាជាទ្រឹស្តីបរន្តេនិយម។ នៅក្នុងក្របខ័ណ្ឌនេះ ពាក្យកម្លាយមានសំណេរបែបណាគឺអនុលោមតាមផ្នត់ក្នុងបរន្តេកម្មជាមួយនឹងឫស ហើយដែលផ្នត់នោះអាចចាត់ទៅតាមទម្រង់ផ្សេងៗ តែទម្រង់នេះមិនមានតួនាទីក្នុងការកម្លាយពាក្យទេ ពោលគឺមិនមែនជាកត្តាកំណត់សំណេរពាក្យកម្លាយនោះឡើយ។

មុនការបង្កើតឡើងនូវគោលការណ៍អាស្រ័យផ្នត់ អ្នកអក្សរសាស្ត្រខ្មែរជំនាន់មុនបានយល់ថាសំណេរនៃពាក្យកម្លាយត្រូវអនុលោមទៅតាមសំណេរនៃពាក្យឫស ពោលគឺប្រសិនបើឫសមានសំណេរជាព្យាង្គរាយនោះ ពាក្យកម្លាយត្រូវមានសំណេរជារាយព្យាង្គ ហើយប្រសិនបើពាក្យឫសមានសំណេរជាព្យាង្គតំរួតវិញនោះ ពាក្យកម្លាយត្រូវមានសំណេរជាតំរួតព្យាង្គ។ ជារួម គោលករណ៍នេះបានកំណត់យកសំណេរពាក្យឫសដែលមិនមានអនុលោមភាពនោះ ធ្វើជាមូលហេតុនៃការកំណត់សំណេរពាក្យកម្លាយ។ ករណីនេះត្រូវបានគេដឹងឮក្នុងរូបភាពជាគោលការណ៍អាស្រ័យឫសឬគោលការណ៍សម្តេច ជួន ណាត ដែលខ្លឹមសារនោះមានចែងនៅក្នុងនិទានរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ស្ថិតនៅខាងដើមនៃវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនាឆ្នាំ១៩៦៧។

ការសិក្សាជាប្រព័ន្ធទៅលើសំណេរនៃពាក្យកម្លាយតាមរយៈប្រធានបទ នៃនិក្ខេបបទនេះនាំមកនូវការយល់ដឹងពីមូលហេតុដែលនាំឱ្យពាក្យកម្លាយមានសំណេរជារាយព្យាង្គនិងជាតំរួតព្យាង្គ

ព្រមទាំងបានស្គាល់យល់ច្បាស់ពីគោលការណ៍ទាំងពីរខាងលើ ៖ គោលការណ៍អាស្រ័យផ្នត់ដែលគេហៅម្យ៉ាងទៀតថាជាគោលការណ៍ច័ន្ទ សំណព្វ មានភាពសុក្រឹតភាពនិងគ្មានករណីផ្ទុយឬករណីលើកលែងឡើយ ហើយមានសកលភាពគ្របដណ្តប់លើសំណោរពាក្យកម្លាយទាំងអស់។ គោលការណ៍នេះមានលក្ខណៈជាសត្យានុម័ត ដែលវិធាននីមួយៗត្រូវបានទាញចេញពីបាតុភូតដែលកើតចេញពីការឈ្វេងយល់ពីយន្តការនៃភាសាខ្មែរព្រមទាំងមានភាពប្រាកដនិយម ដែលអាចអនុវត្តលើគ្រប់ពាក្យកម្លាយទាំងអស់។ ផ្ទុយទៅវិញគោលការណ៍អាស្រ័យឫសឬគោលការណ៍សម្តេចព្រះសង្ឃរាជ ជួន ណាត មានអតក្កភាពប្រាំយ៉ាង ហើយមិនបានឆ្លុះបញ្ចាំងពីប្រាកដភាពនិងការឆ្លើយតបទៅនឹងសំណោរពាក្យកម្លាយក្នុងភាសាខ្មែរទេ។ ប្រការនេះបណ្តាលមកពីការសន្មតបង្កើតគោលការណ៍នេះឡើងគឺផ្អែកលើភាពអត្តនោម័ត ដោយមិនបានផ្អែកលើការពិនិត្យ ពិចារណានិងការផ្ទៀងផ្ទាត់នោះឡើយ។

តាមការសិក្សាលើប្រធានបទនៃនិក្ខេបបទនេះ យើងឃើញថាសំណោរនៃពាក្យកម្លាយត្រូវកំណត់ជាផ្លូវការដោយផ្អែកលើសំណោរនៃពាក្យឫសចាប់តាំងឆ្នាំ១៩៦៧មក តាមរយៈការចែងជាវិធាននៅក្នុងនិទាននៃវចនានុក្រមដែលអក្ខរាវិរុទ្ធនៃពាក្យកម្លាយទាំងអស់ត្រូវកត់ត្រាទុក ទោះបីជាវាមិនមានតក្កភាព(logic)ក៏ដោយចុះ។ ប៉ុន្តែ ក្នុងក្របខ័ណ្ឌនៃការសិក្សាស្រាវជ្រាវតាមបែបភាសាវិទ្យានិងតាមទ្រឹស្តីបរន្តេនិយម ដែលកត្តាសត្យានុម័តតម្រូវជាចាំបាច់នោះ យើងយល់ឃើញថាសំណោរនៃពាក្យឫសមិនមែនជាកត្តាកំណត់សំណោរនៃពាក្យកម្លាយទេ។ ផ្ទុយទៅវិញ គឺផ្នត់នៅក្នុងបរន្តេកម្មជាមួយនឹងឫសទៅវិញទេ ដែលជាចលករពិតប្រាកដក្នុងការកំណត់សំណោរនៃពាក្យកម្លាយនោះ។

ការប្រឈមទស្សនៈនានា ជាពិសេស ការសិក្សាប្រៀបធៀបគោលការណ៍អាស្រ័យឫសទៅនឹងគោលការណ៍អាស្រ័យផ្នត់តាមរយៈនិក្ខេបបទនេះ បាននាំមកជាពន្លឺក្នុងការយល់ដឹងពីមូលហេតុពិតប្រាកដដែលនាំឱ្យពាក្យកម្លាយមានសំណោរជារាយព្យាង្គ ជាតំរួតព្យាង្គ ឬជាព្យាង្គតំរួត។ ការសន្និដ្ឋានពីសំណោរនៃពាក្យកម្លាយក្នុងករណីនីមួយៗមានលក្ខណៈជាសកល ប្រកបទៅដោយសនិទានកម្ម ហើយកើតចេញពីវិចារណកម្មដ៏ពិតប្រាកដ ដូចមានបង្ហាញជូនតាមលំដាប់លំដោយនៅក្នុងនិក្ខេបបទនេះស្រាប់។

លទ្ធផលនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះ នឹងនាំមកនូវវិភាគទានមួយបន្ថែមទៀតក្នុងការចូលរួមចំណែកក្នុងការយល់ដឹងពីយន្តការនៃភាសាខ្មែរ ដែលទាក់ទងដោយផ្ទាល់ទៅនឹងការកំណត់សំណោរនៃពាក្យកម្លាយ ព្រមទាំងដើមចមនានាដែលត្រូវបានឈ្វេងយល់ជាបែបសត្យានុម័តឬកំណត់យកតាមបែបអត្តនោម័ត ដើម្បីធ្វើជាអំណះអំណាងទៅលើអក្ខរាវិរុទ្ធនៃពាក្យកម្លាយក្នុងភាសាខ្មែរនេះ។

**Summary**

To write derivative words in រាយព្យាង្គ and in តំរួតព្យាង្គ is a problem that has occured in the Khmer language in these past decades. For instance, *បំការ លំអ សំអាង* are written in រាយព្យាង្គ but they are from differentphenomena, whereas in comparison, *បង្ការ លម្អ សម្អាង* are written in តំរួតព្យាង្គ. បំការ is a historical word that is not defined in Chuon Nath's dictionary like បង្ការ. Both *លំអ and លម្អ* are defined in the dictionary as the same word, which means they share the same definition. These two cases are different from *សំអាង* and *សម្អាង*, in which they are defined in the dictionary as two separate words that have different meanings.

The origin of whether derivative words should be written in រាយព្យាង្គ and in តំរួតព្យាង្គ has been clearly identified in Dependent on affix principle (គោលការណ៍អាស្រ័យផ្នត់) which is according to Chan Somnoble's theory, also known as Extintraism theory. Within this theory's framework, how a derivative word is written is in compliance with affixes in Extation (បវេន្តកម្ម) with roots, and these affixes can be in different forms though their forms do not play a role in derivating a word. In other words, their forms are not a factor that decides how a derivative word is written.

Before the establishment of Dependent on affix principle (គោលការណ៍អាស្រ័យផ្នត់), Khmer linguistics in the past were confused that a derivative word should be written according to its root, that is if the root is written in non subscribe syllable (ព្យាង្គរាយ) then the derivative word is to be written in រាយព្យាង្គ, and if the root is written in subscribe syllable (ព្យាង្គតំរួត) then the derivative word is to be written in តំរួតព្យាង្គ. This principle settles that the writing of radical (សំណេរពាក្យឫស) which is not in compliance with how a root is written is a reason to decide how a derivative word is spelled. This principle is known as dependent on radical principal (គោលការណ៍អាស្រ័យឫស) or Chuon Nath's Principle, which is stated by Chuon Nath in the preface of Khmer Dictionary, 5th edition, published by Buddha Institut in 1967.

A study on how derivative words is written in this thesis topic leads to a better understanding of the cause that guides a derivative word to be written in រាយព្យាង្គ and in តំរួតព្យាង្គ and how the two principles work: Dependent on affix

principle (គោលការណ៍អាស្រ័យផ្នត់) or Chan Somnoble's Principle is accurate, without any oppositions or exceptions, and the principle has a global coverage on all derivative words. This principle has approval characteristics, in which each rule has been concluded from phenomena arising from the understanding of mechanism of the Khmer language, and each rule is realistic. Nevertheless, dependent on radical principal (គោលការណ៍អាស្រ័យឫស) or Chuon Nath's Principle contains five faults, and the principle does not reflect the truth of derivative words in the Khmer language. This is because the creation of this principle is based on subjectivity without any review, consideration, and verification.

Based on the study of this thesis topic, it can be seen that the spelling of derivative words has been set officially to be in accordance with how their roots are written since 1967, as evidenced in the preface of a dictionary that notes all the spelling of derivative words even though they do not have any logic. However, within the framework of this linguistic study and based on Extintration (បរន្តេកម្ម) theory, which requires approval factors, we can see that the spelling of root words is not a factor that decides the spelling of their derivatives. On the contrary, affixes in Extintration (បរន្តេកម្ម) with roots is the real drive in determining how derivative words are written.

Opposing views, especially a study comparing dependent on radical principal (គោលការណ៍អាស្រ័យឫស) and Dependent on affix principal (គោលការណ៍អាស្រ័យផ្នត់) in this thesis has shed light upon the understanding of the real cause that leads to the spelling of derivative words in រាយព្យាង្គ, តំរួតព្យាង្គ, or ព្យាង្គតំរួត. The conclusion on the spelling of derivative words in each case has a global characteristic, with reasoning, and it arises out of rationality as demonstrated orderly in this thesis.

The result of a study on this topic brings an additional contribution to the understanding of mechanisms of the Khmer language, which relates directly to the determination of derivative words' spelling as well as the principles that have approval characteristics or based on subjectivity to decide the spelling of derivative words in the Khmer language.

# អារម្ភកថា

ប្រធានបទដែលបានលើកយកមកសិក្សាវិភាគស្ដីពី *ការសិក្សាពីសំណេរពាក្យកម្លាយនៃភាសាខ្មែរទំនើបក្នុងក្របខ័ណ្ឌ : សំរាយតំរួត* ដែលជាសមិទ្ធិនៃការសិក្សានៅថ្នាក់បណ្ឌិតលើមុខវិជ្ជាភាសាវិទ្យា នៅរាជបណ្ឌិត្យសភាកម្ពុជា។

នៅក្នុងនិក្ខេបបទនេះ យើងបានយកគោលការណ៍និងទស្សនៈមួយចំនួនដែលបាននិយាយពីការកម្លាយពាក្យខ្មែរមកសិក្សាប្រៀបធៀបនិងវិភាគដើម្បីរកឱ្យឃើញនូវប្រាកដភាព ដែលបានកើតមាននៅក្នុងគោលការណ៍និងទស្សនៈនីមួយៗនោះ។

ជាប្រធានបទ ដែលត្រូវបានជ្រើសរើសយកមកសិក្សាក្នុងខណៈដែលបញ្ហានៃការសរសេររាយត្រួតបាននិងកំពុងចោទមានឡើង ហើយក្លាយជាបញ្ហាប្រកបដោយបច្ចុប្បន្នភាពនិងក្ដៅគគុកនៃសំណេរពាក្យខ្មែរជាសាធារណៈ។ ទន្ទឹមនឹងនេះ ទស្សនៈឬការយល់ឃើញបែបប្រឈមគ្នាលើសំណេរទាំងពីរ កំពុងតែកើតមានក្នុងស្រទាប់អ្នកអក្សរសាស្ត្រនិងជាពិសេសក្នុងចំណោមអ្នកដែលគ្រាន់តែប្រកាន់តាមសៀវភៅឬវចនានុក្រមណាមួយ ដោយមិនបានពិចារណារកហេតុផលនិងយល់ដឹងពីកត្តាកំណត់ពីសំណេរនីមួយៗ ហើយយកការប្រកាន់តាមអ្នកនេះឬអ្នកនោះមកធ្វើជារបាំងការពារមតិរបស់ខ្លួន។

ហេតុនេះ ការជ្រើសរើសប្រធានបទនេះមកសិក្សាគឺពិតជាមានសារប្រយោជន៍មិនត្រឹមតែចំពោះតែយើងដែលជាម្ចាស់នៃនិក្ខេបបទដែលមានជំនក់ចិត្តដំណិតអារម្មណ៍លើបញ្ហានេះប៉ុណ្ណោះទេ តែវាក៏មានសារៈសំខាន់ដល់អ្នកសិក្សាស្រាវជ្រាវដទៃទៀតដែលមានចម្ងល់ទៅលើសំណេរពាក្យខ្មែរក្នុងក្របខ័ណ្ឌសំរាយតំរួតនេះដែរ។ ម្យ៉ាងទៀត ការនាំមកនូវប្រត្យក្សភាពខាងផ្នែកសំណេរពាក្យកម្លាយនៃភាសាខ្មែរ នឹងនាំទៅដល់ការប្រើប្រាស់ពាក្យប្រកបដោយសុក្រឹតភាពនិងឯកភាពខាងផ្នែកសំណេរផងដែរ។

ប្រការទាំងអស់នេះហើយ ដែលធ្វើឱ្យយើងខ្ញុំចាប់ចិត្តគិតផ្ដោតអារម្មណ៍លើសំណេរពាក្យកម្លាយក្នុងភាសាខ្មែរនាពេលបច្ចុប្បន្ន ហើយសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះដោយយកគោលការណ៍អាស្រ័យផ្នត់មកជាបទដ្ឋានក្នុងការសិក្សា។

គោលការណ៍អាស្រ័យផ្នត់បានផ្ដល់ជាការវិភាគមួយថា សំណេរនៃពាក្យកម្លាយអាស្រ័យទៅលើផ្នត់ក្នុងបរន្តកម្មជាមួយនឹងពាក្យឫស។ ទន្ទឹមនឹងនេះ ស្ថាបនិកនៃទ្រឹស្ដីបរន្តនិយមបានផ្ដល់ជូននូវគោលការណ៍អាស្រ័យផ្នត់ ដែលកំណត់ពីសំណេរនៃពាក្យកម្លាយក្នុងភាសាខ្មែរ ហើយគោលការណ៍របស់គាត់មិនមានករណីលើកលែងទេ ព្រមទាំងមានលក្ខណៈសុក្រឹតនៅក្នុងការផ្ទៀងផ្ទាត់គ្រប់ករណីទៀតផង។

នៅក្នុងការសិក្សាស្ដីពី សំណេរពាក្យកម្ចាយនៃភាសាខ្មែរទំនើបក្នុងក្របខ័ណ្ឌ : សំរាយតំរួតនេះ ស្មេរបានប្រមូលទិន្នន័យពីប្រភពនានាដែលពាក់ព័ន្ធដូចជា សំណេរពាក្យកម្ចាយក្នុងវចនានុក្រម សំណេរពាក្យកម្ចាយក្នុងសៀវភៅសិក្សានិងឯកសារនានា សំណេរពាក្យកម្ចាយជាឈ្មោះឬជាប្រពៃណី និងសំណេរពាក្យកម្ចាយក្នុងក្របខ័ណ្ឌសំរាយតំរួត។

យើងក៏យល់ឃើញផងដែរថា សំណេរពាក្យមានសារៈសំខាន់ណាស់សម្រាប់ខ្មែរគ្រប់រូប ហើយការសរសេរពាក្យឱ្យបានត្រឹមត្រូវជាកត្តាចាំបាច់បំផុតនៅក្នុងការសរសេរប្រាស្រ័យទាក់ទងគ្នា ការបោះផ្សាយជាផ្លូវការនិងការផ្សព្វផ្សាយជាសាធារណៈ ពីព្រោះការសរសេរមិនបានត្រឹមត្រូវនាំឱ្យប្រាសចាកន័យ ខុសខ្លឹមសារ ព្រមទាំងធ្វើឱ្យមានសភាពស្រអាប់ក្នុងវិស័យអក្សរសាស្ត្រខ្មែរ។ ហេតុនេះហើយ យើងមានបំណងចូលរួមចំណែកក្នុងការសិក្សាវិភាគនិងស្រាយបញ្ហាដែលកើតមានជាប្រចាំរាល់ថ្ងៃ ដោយមានជំនឿជឿជាក់ថា អាចជាបច្ច័យមួយដែលអាចជួយបំពេញភាពខ្វះខាតនិងអាចជំរុញនិងលើកស្ទួយអក្សរសាស្ត្រខ្មែរឱ្យបានរុងរឿងមួយកម្រិតថែមទៀត។

ការសិក្សាលើប្រធានបទនេះ គឺក្នុងគោលបំណងនាំមកនូវសម្មតិកម្មមួយដែលជាវិភាគទានក្នុងការអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ ឱ្យបានគង់វង្សយូរអង្វែងប្រកបដោយសុក្រឹតភាព ការឯកភាពជាធ្លុងមួយនិងអាចឈានទៅរកការទប់ស្កាត់កំហុស ដែលធ្លាប់កើតមានក្នុងពេលកន្លងមក។

ដោយផ្អែកលើទ្រឹស្ដីបរន្តេនិយម សំណេរពាក្យកម្ចាយក្នុងក្របខ័ណ្ឌសំរាយតំរួតនេះក៏បានផលិតសមិទ្ធិដែលជាសម្មតិកម្មថ្មីមួយ។ ជារួម ការសិក្សាស្រាវជ្រាវលើប្រធានបទនេះនឹងអាចឱ្យយើងខ្ញុំមានគំនិតកាន់តែទូលាយលើសំណេរពាក្យកម្ចាយក្នុងភាសាខ្មែរ ជាពិសេស ហេតុផលដែលនាំឱ្យមានសំណេរបែបរាយព្យាង្គ តំរួតព្យាង្គ ឬព្យាង្គតំរួត ដោយឈរលើមូលដ្ឋាននៃតួនាទីផ្ទត់ក្នុងបរន្តេកម្មជាមួយនឹងពាក្យឫស នៅពេលយន្តការនៃការបង្កើតពាក្យតាមរយៈវិធីកម្ចាយដែលមានលក្ខណៈជាខ្មែរ។